ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# សុន្ទរកថា

ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានគណៈកម្មាធិការសម្របសម្រួលប្រចាំប្រទេស
ក្នុងកិច្ចប្រជុំពិគ្រោះយោបល់អំពីជំងឺរបេង ៖ កិច្ចសន្ទនាប្រចាំប្រទេសឆ្នាំ២០១៤

ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤

សណ្ឋាគារ តារាអ៊ែរផត

- ឯកឧត្តម លោកជំទាវ ជាគណៈអធិបតី
- លោកវេជ្ជបណ្ឌិត Dong-Il Ahn អ្នកតំណាងអង្គការសុខភាពពិភពលោកប្រចាំកម្ពុជា និង ជាអនុប្រធាន CCC
- ឯ.ឧ. វេជ្ជបណ្ឌិត ម៉ៅ តាន់ អៀង នាយកមជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺរបេង និង ហង់សិន
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាសមាជិក សមាជិកា អង្គប្រជុំទាំងអស់

ជាបឋមតាងនាមគណៈកម្មាធិការសម្របសម្រួលប្រចាំប្រទេសកម្ពុជា និង ក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅ និង ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ដែលបានអញ្ជើញចូលរួមនៅក្នុងអង្គប្រជុំដ៏មានសារៈសំខាន់នាពេលនេះ ដើម្បីរៀបចំចងក្រងឯកសារកំណត់បង្ហាញទស្សនៈអំពីជំងឺរបេង (Tuberculosis Concept Note) តាមគំរូហិរញ្ញប្បទានថ្មីរបស់មូលនិធិសកល។ ថ្ងៃនេះយើងជួបជុំគ្នា ដើម្បីពិគ្រោះយោបល់អំពីជំងឺរបេង ដែលជាកិច្ចសន្ទនាប្រចាំប្រទេសកម្ពុជាឆ្នាំ២០១៤ រកឱ្យឃើញអតិភាវូបនីយកម្មសកម្មភាពសម្រាប់កំណត់បង្ហាញ

ទស្សនៈ ។ ក្រុមការងារចំនួន ១២ ដែលនឹងត្រូវបង្កើតឡើងដើម្បីពិភាក្សាលើសេចក្តីព្រាង កំណត់បង្ហាញទស្សនៈនឹងត្រូវពិគ្រោះគ្នាអំពី ៖ ១) ការរកឃើញ និង ការធ្វើរោគវិនិច្ឆ័យករណីជំងឺរបេង ២) ការព្យាបាល និង ការបង្ការ ៣) ការចូលរួមពិភាក្សាក្នុងចំណោមអ្នកផ្តល់សេវាថែទាំទាំងអស់ ៤) ការផ្តល់នូវការថែទាំជំងឺរបេងតាមសហាគមន៍ ៥) សកម្មភាពសហប្រតិបត្តិការជាមួយកម្មវិធី និង វិស័យផ្សេងៗទៀត ៦) សកម្មភាពរួមរបេង/អេដស៍ ៧) សកម្មភាពជំងឺរបេងដែលប្រឆាំងឱសថច្រើនមុខ ៨) ការដកចេញនូវរបាំងចំពោះសិទ្ធិទទួលបាន/ហិរញ្ញវត្ថុថែទាំសុខភាព ៩) ប្រព័ន្ធព័ត៌មានសុខភាព និង ការតាមដាន និង វាយតម្លៃ ១០) ការគ្រប់គ្រងកម្មវិធី/ការគ្រប់គ្រងសង្វាក់ផ្គត់ផ្គង់លទ្ធកម្ម ១១) យោបល់ត្រឡប់ពីប្រជាជនដែលប៉ះពាល់សំខាន់ៗ និង ១២) យោបល់ត្រឡប់ពីរចនាសម្ព័ន្ធសុខភាពផ្អែកលើមូលដ្ឋានសហាគមន៍ ។

ដូចដែលយើងទាំងអស់គ្នាបានដឹងហើយថា ហិរញ្ញប្បទានបណ្តោះអាសន្នសម្រាប់ជំងឺរបេងមានចំនួន ៣លានដុល្លារអាម៉េរិក អាចបន្តដំណើរការរហូតដល់ដំណាច់ឆ្នាំ២០១៤ ក៏ប៉ុន្តែការរៀបចំឱ្យមាននូវកំណត់បង្ហាញទស្សនៈ ដែលមានលក្ខណៈស្តង់ដារមួយនឹងបន្តធានាឱ្យមាននូវការផ្តល់ហិរញ្ញប្បទានសម្រាប់រយៈពេល៣ឆ្នាំខាងមុខទៀត ។ ដូច្នេះដើម្បីជៀសវាងនូវការកាត់ផ្តាច់ហិរញ្ញប្បទាន គណៈកម្មាធិការសម្របសម្រួលប្រចាំប្រទេសបានសម្រេចដាក់ជូននូវកំណត់បង្ហាញទស្សនៈពេញលេញមួយ ទៅមូលនិធិសកលឱ្យបានមុនថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៤ ដែលជាជម្រើសអាចនឹងសម្រេចបាន ។

ក្នុងគំរូហិរញ្ញប្បទានថ្មី មានសមាសធាតុសំខាន់ពីរដែលជាប់ពាក់ព័ន្ធនឹងការរៀបចំកំណត់បង្ហាញទស្សនៈ ៖ ១) ការរៀបចំតាក់តែងនូវសំណើបច្ចេកទេសមួយដោយផ្អែកលើមូលដ្ឋានផែនការយុទ្ធសាស្ត្រជាតិ និង ២) ដំណើរការកិច្ចសន្ទនាប្រចាំប្រទេសដែលអនុញ្ញាតឱ្យដៃគូពហុភាព អ្នកពាក់ព័ន្ធ និង អ្នកនៅតាមមូលដ្ឋានផ្តល់នូវធាតុចូលរបស់ពួកគេក្នុងការតាក់តែងកម្មវិធីចុងក្រោយ និង សកម្មភាពអតិភាវូបនីយកម្ម ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា*

ខ្ញុំសង្ឃឹមថាការប្រជុំពិភាក្សារយៈពេលពីរថ្ងៃដែលយើងកំពុងធ្វើនេះ នឹងផ្តល់ជាលទ្ធផលដែលនាំឱ្យយើងរៀបចំបាននូវ កំណត់បង្ហាញទស្សនៈអំពីជំងឺរបេងដ៏សមស្រប ដើម្បីធានានូវការទទួលបានហិរញ្ញប្បទានពីមូលនិធិសកល ក្នុងការប្រយុទ្ធនឹងជំងឺរបេងសម្រាប់រយៈពេល ៣ឆ្នាំខាងមុខ ។

ខ្ញុំជឿជាក់ថាតាមរយៈកិច្ចប្រជុំពិគ្រោះយោបល់ថ្ងៃនេះឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ នឹងផ្តល់នូវធាតុចូលដ៏មានសារៈសំខាន់ដើម្បីរួមចំណែកក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺដ៏កំណាចនេះ ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និង អ្នកចូលរួមទាំងអស់ សូមមានសុខភាពល្អ កម្លាំងមាំមួន និង ប្រាជ្ញាឈ្លៀសវៃ និង ជួបប្រទះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ព្រមទាំងសូមកោតសរសើរផងដែរចំពោះសមាជិក-សមាជិកាទាំងអស់ នៃគណៈកម្មការរៀបចំអង្គពិធី និង ម្ចាស់មូលនិធិសកល ដែលបានរួមចំណែកគាំទ្រដល់ការរៀបចំសិក្ខាសាលាដ៏មានសារសំខាន់នាថ្ងៃនេះ ។

ខ្ញុំសូមប្រកាសបើក កិច្ចប្រជុំពិគ្រោះយោបល់អំពីជំងឺរបេង ៖ កិច្ចសន្ទនាប្រចាំប្រទេសឆ្នាំ២០១៤ ចាប់ពីពេលនេះតទៅ។

*សូមអរគុណ!*